00207430

A190/I/1

០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ១១)

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)**
**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ ១១) |
| ឈ្មោះសំណុំរឿង: | ខៀវ សំផន |
| ដាក់តំកល់ជូន: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទដាក់ឯកសារ: | ថ្ងៃទី២២ ខែកក្កដា ២០០៨ |
| ភាគីអ្នកតម្កល់: | ក្រុមការពារក្តី |
| ភាសា: | ភាសាដើមជាភាសាបារាំង បកប្រែជាភាសាខ្មែរ(ក្រៅផ្លូវការ) |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 22 / 07 / 2008
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

# សារណាបណ្តឹងឧទ្ធរណ៍របស់ក្រុមការពារក្តី ចំពោះការបដិសេធសំណើសុំ បកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន

**បញ្ជូនដោយ:**

**មេធាវីរបស់លោក ខៀវ សំផន**

លោក ស សូវាន

លោក Jacques VERGÈS

**អ្នកជំនួយការៈ**

កញ្ញា MOREAU Charlotte

អ្នកស្រី សេង សុជាតា

**បញ្ជូនទៅ:**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន័យ ផុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUI

លោក Rowan DOWNING

**ការិយាល័យសហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 23 / July / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

# គោរពជូនអង្គបុរេជំនុំជម្រះ

## I. សេចក្តីផ្តើម និង សំណើ

១. តាមរយៈដីកាសម្រេចចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៨[1] សហចៅក្រមស៊ើបអង្កេតបានសម្រេចបដិសេធសំណើរបស់លោក ខៀវ សំផន ដើម្បីនឹងទទួលបាននូវសេចក្តីបកប្រែទាំងស្រុងនៃសំណុំរឿងព្រហ្មទណ្ឌរបស់គាត់[2]។

២. សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថាសេចក្តីសម្រេចរបស់ខ្លួនគឺជាការបង្ហាញឱ្យឃើញពីបរាជ័យ៖ "សិទ្ធិទទួលបានការជំនុំជម្រះក្នុងពេលវេលាមួយសមស្របនឹងត្រូវបានប៉ះពាល់យ៉ាងខ្លាំងប្រសិនបើឯកសារទាំងអស់ដែលមាននៅក្នុងសំណុំរឿង ត្រូវបានទាមទារឱ្យមានការបកប្រែទៅជាបីភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងារ អ.វ.ត.ក។"[3]

៣. តាមរយៈការកត់សម្គាល់ខាងលើនេះ សហចៅក្រមស៊ើបអង្កេតបង្ហាញនូវវិធានការដូចតទៅនេះ៖ នៅក្នុងដំណាក់កាលស៊ើបអង្កេត ការបកប្រែសំណុំរឿងព្រហ្មទណ្ឌធ្វើឡើងតែត្រឹមអត្ថបទនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ កំណត់សម្គាល់នៅផ្នែកខាងក្រោមទំព័រ(notes de bas de page) និងលិបិក្រមនៅក្នុងសៀវភៅ(indexes) ដែលជាអត្ថបទនៃឯកសារដែលគាត់តែងឡើងទាំងស្រុងដោយសហព្រះរាជអាជ្ញាប៉ុណ្ណោះ។ ការបកប្រែភស្តុតាងពិតប្រាកដត្រូវបានគ្រោងទុកតែនៅក្នុងដំណាក់កាលបិទបញ្ចប់ការស៊ើបអង្កេតតែប៉ុណ្ណោះ[4]។

៤. ដោយដឹងថាការកំណត់ឱ្យបកប្រែខាងលើមានការប៉ះពាល់ជាចាំបាច់ចំពោះសិទ្ធិរបស់ជនត្រូវចោទ[5]នោះ សហចៅក្រមស៊ើបអង្កេតក៏ស្នើចំពោះគ្រប់ភាគីទាំងអស់ ជាពិសេសក្រុមការពារក្តី និងជនជាប់ចោទខ្លួនឯង ឱ្យពិនិត្យមើលការពិតជាក់ស្តែង៖ ដោយហេតុថា អ.វ.ត.ក.មិនអាចបកប្រែ

---

[1] "ដីកាសម្រេចស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ" ១៩ ខែមិថុនា ឆ្នាំ២០០៨ (តទៅនេះ "ដីកាសម្រេច")

[2] កថាខ័ណ្ឌ ឃ ១ នៃដីកាសម្រេច

[3] កថាខ័ណ្ឌ ក ៣ នៃដីកាសម្រេច

[4] កថាខ័ណ្ឌ ខ ៤ នៃដីកាសម្រេច

[5] កថាខ័ណ្ឌ ក ៣ នៃដីកាសម្រេច

ឯកសារទាំងអស់បាន ជនត្រូវចោទព្រមទាំងក្រុមការពារក្តីរបស់ខ្លួនត្រូវបានស្នើសុំឲ្យ "សហការ" ជាមួយផ្នែករដ្ឋបាល។ ដូច្នេះ ដោយស្ថិតនៅក្រោមការត្រួតពិនិត្យរបស់សហចៅក្រមស៊ើបអង្កេត និងដោយមានជំនួយពីអ្នកបកប្រែម្នាក់ លោក ខៀវ សំផន ត្រូវទទួលបន្ទុកសម្រាំងជ្រើសរើសភស្តុតាងដែលគាត់យល់ថា សមហេតុសមផល និងមានលក្ខណៈជាអាទិភាពសម្រាប់ការបកប្រែ ហើយការធ្វើដូច្នេះគឺសម្រាប់រឿងក្តីផ្ទាល់ខ្លួនរបស់គាត់!

៥. ក្រុមការពារក្តីចោទសួរខ្លួនឯងថា៖ តើនេះគឺពិតជាតួនាទីរបស់លោក ខៀវ សំផនឬ? តើលោក ខៀវ សំផន ត្រូវបានចាត់ទុកថាគ្មានពិរុទ្ធភាពមែនឬ?

៦. ដោយផ្ទុយទៅនឹងអ្វីដែលសហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ គឺពិតជាមិនមែនគោលការណ៍នៃសិទ្ធិក្នុងការទទួលបានការជម្រះក្តីប្រកបដោយភាពយុត្តិធម៌នោះទេដែលនាំទៅដល់សេចក្តីសម្រេចរបស់ខ្លួន ប៉ុន្តែគឺជាការពិនិត្យពិចារណាទៅលើថវិការងណោះវិញទេ!

៧. សហមេធាវីនៃក្រុមការពារក្តីឲ្យលោក ខៀវ សំផន សូមបញ្ជាក់ថា៖

- ការបដិសេធមិនបង្គាប់ឲ្យបកប្រែទាំងស្រុងនូវសំណុំរឿងរបស់លោក ខៀវ សំផន គឺខ្វះមូលដ្ឋានច្បាប់។
- អវត្តមានការបកប្រែ និងវិធានការបង្គាប់បញ្ជា គឺប៉ះពាល់យ៉ាងធ្ងន់ធ្ងរទៅដល់សិទ្ធិរបស់លោក ខៀវ សំផន។
- ដូច្នេះ ការឃុំខ្លួនលោក ខៀវ សំផន គឺគ្មានហេតុផល ហើយគាត់ត្រូវតែត្រូវបានដោះលែងឲ្យមានសេរីភាព។

៨. ដូច្នេះ ដោយអនុវត្តន៍តាមវិធាន ៧៤-៣ ខ) សហមេធាវីក្រុមការពារក្តីសូមស្នើទៅអង្គបុរេជំនុំជម្រះ មេត្តា៖

⇒ **ទុកជាមោឃៈ**ដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដោយសារតែកង្វះមូលដ្ឋានច្បាប់

⇒ **កត់សម្គាល់**ចំពោះការរំលោភបំពានសិទ្ធិរបស់លោក ខៀវ សំផន ដែលកើតមានឡើងដោយសារតែអវត្តមាននៃការបកប្រែ

⇒ ដោយហេតុដូច្នេះ **បង្គាប់ឲ្យមានការដោះលែង**ជាបន្ទាន់និងដោយគ្មានលក្ខខណ្ឌលោក ខៀវ សំផន។

## II. អង្គហេតុ និង នីតិវិធី

៩. នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញាបានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ហើយបានស្នើឱ្យចាប់ខ្លួន និងឃុំខ្លួនជាបណ្ដោះអាសន្ននូវជនសង្ស័យចំនួន ៥ រូប ដែលនៅក្នុងនោះ មានលោក ខៀវ សំផន ផងដែរ។ ឯកសារដែលដាក់បញ្ចូលទៅក្នុងសំណុំរឿងព្រហ្មទណ្ឌដោយ សហព្រះរាជអាជ្ញា គឺមានចំនួនដ៏ច្រើនសម្បើម៖ ចំនួន ១៣៥ កម្រងឯកសារ (classeurs) ត្រូវ បានភ្ជាប់ជាឧបសម្ព័ន្ធ ដើម្បីបង្ហាញភស្តុតាងអំពីភាពទទួលខុសត្រូវរបស់ជនសង្ស័យទាំង៥រូប។ ហើយភាគច្រើនបំផុតនៃឯកសារនោះមានតែជាភាសាខ្មែរប៉ុណ្ណោះ។ មានឯកសារជាភាសា អង់គ្លេសប្រហែល៣០% ហើយ ១០% ជាភាសាបារាំង[6]។ ដូច្នេះ ឯកសារទាំងនោះមិនមាននៅ ក្នុងភាសារបស់លោក VERGÈS ដែលជាមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន ទេ។

១០. នៅថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ លោក ខៀវ សំផន ត្រូវបានឃុំខ្លួនជាបណ្ដោះអាសន្ន "ទៅតាម ឯកសារ និងការបញ្ជាក់អះអាងរបស់សាក្សីជាច្រើនដែលមាននៅក្នុងសំណុំរឿង"[7]។

១១. នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០០៨ នៅក្នុងពេលសាកសួរកូនក្ដីរបស់ខ្លួន លោក VERGÈS មានការខឹង សម្បារ៖ "រហូតមកទល់ថ្ងៃនេះ ឯកសារចំនួន ១៦ ០០០ ទំព័រ ដែលជាឧបសម្ព័ន្ធនៃដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរ មិនត្រូវបានគេបកប្រែជាភាសាបារាំងទេ ខណៈដែលវាភាសាជាផ្លូវការ មួយក្នុងចំណោមភាសាផ្លូវការទាំងបីរបស់តុលាការ (...)។ ដរាបណាការបកប្រែទាំងនោះមិនត្រូវ បានធ្វើទេនោះ [ក្រុមការពារក្ដី] [នឹង]នៅតែបន្តធ្វើការបដិសេធ[របស់ខ្លួន] ក្នុងការឆ្លើយតបទៅ នឹងសំណួរផ្សេងៗ"[8]។ នៅក្នុងពេលស៊ើបសួរដដែលនោះ លោក Alexander Bates ជាជំនួយការ សហព្រះរាជអាជ្ញាបានបញ្ជាក់ថា "ទំព័រនីមួយៗគួរតែត្រូវបានបកប្រែជាភាសាផ្លូវការនីមួយៗ"[9]។

---

[6] សូមអាន ឧបសម្ព័ន្ធ ១ - អ៊ីម៉ែលរបស់លោក Charles K. Muraya ជាប្រធានអង្គភាពទទួលបន្ទុកឯកសារ ទៅ សេង សុជាតា អ្នកគ្រប់គ្រងសំណុំរឿងរបស់លោក ខៀវ សំផន ដែលអ៊ីម៉ែលនោះផ្ដល់នូវស្ថិតិឯកសារជាភាសាផ្លូវការ ផ្សេងៗ។

[7] រឿងក្ដី ខៀវ សំផន "ដីកាសម្រេចឱ្យឃុំខ្លួនជាបណ្ដោះអាសន្ន" កថាខ័ណ្ឌ ៥ ឯកសារតុលាការ C26 ERN 00152991-00152996។

[8] រឿងក្ដី ខៀវ សំផន "កំណត់ហេតុសាកសួរចម្លើយ" ឯកសារតុលាការ D75 ERN 00164223-00164225

[9] រឿងក្ដី ខៀវ សំផន "កំណត់ហេតុសាកសួរចម្លើយ" ឯកសារតុលាការ D75 ERN 00164223-00164225

១២. នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ នៅពេលដែលបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្នរបស់លោក ខៀវ សំផន ត្រូវបានបើកសវនាការនៅចំពោះមុខអង្គបុរេជំនុំជម្រះ បញ្ហាទាក់ទងនឹងការបកប្រែនេះមិនទាន់ត្រូវបានដោះស្រាយនៅឡើយទេ។ ដូច្នេះ ដូចដែលលោក VERGÈS បានថ្លែងបញ្ជាក់នៅក្នុងសវនាការនោះ លោក ខៀវ សំផន ជានិច្ចកាលគឺមិនអាចអនុវត្តសិទ្ធិការពារខ្លួនគាត់បានទេ ដោយហេតុតែមេធាវីម្នាក់ក្នុងចំណោមសហមេធាវីរបស់គាត់ គឺសហមេធាវីអន្តរជាតិ មិនអាចទទួលបានឯកសារនៅក្នុងភាសាមួយដែលគាត់អាចយល់បាន។ តាមរយៈសេចក្តីសម្រេចចុះកាលបរិច្ឆេទនៅថ្ងៃដដែលនោះ អង្គបុរេជំនុំជម្រះបានកត់សម្គាល់ស្ថានភាពនេះ ហើយក៏ពន្យារពេលសវនាការទៅកាលបរិច្ឆេទមួយដែលនៅតែមិនទាន់ត្រូវបានកំណត់នៅឡើយ។[10]

១៣. រយៈពេលចំនួនពីរខែបានកន្លងផុតទៅ ក្រុមការពារក្តីឲ្យលោក ខៀវ សំផន បានសួរទៅប្រធានផ្នែកគ្រប់គ្រងរដ្ឋបាលតុលាការថា តើឯកសារសំណុំរឿងលោក ខៀវ សំផន ត្រូវបានបកប្រែជិតហើយឬនៅ[11]។ ក្រុមការពារក្តីមិនបានទទួលចម្លើយណាមួយឡើយ។

១៤. នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ តាមរយៈ "ដីកាសម្រេចស្តីពីសិទ្ធិនិងកាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ" សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងទៅលោក ខៀវ សំផន ថា សហចៅក្រមស៊ើបអង្កេត បានបដិសេធសំណើសុំការបកប្រែរបស់គាត់។

១៥. នៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ សហមេធាវីការពារក្តីបានចុះហត្ថលេខាលើសេចក្តីប្រកាសប្តឹងឧទ្ធរណ៍ជាមួយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត ហើយថ្ងៃនេះ សហមេធាវីការពារក្តីបានដាក់សារណាប្តឹងឧទ្ធរណ៍នេះ។

---

[10] សេចក្តីសម្រេចពន្យារពេលសវនាការ ចំពោះបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចដាក់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ C-26-I-25

[11] សេចក្តីចម្លងនៃសំបុត្រដែលបានផ្ញើរជូន តូនី ក្រាញ់ ស្តីពីបញ្ហានៃការបកប្រែចុះថ្ងៃទី៥ ខែមិថុនា ឆ្នាំ២០០៨ បានផ្ញើរជូនសហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០០៨ A185

## III. បទប្បញ្ញត្តិច្បាប់សមស្រប

១៦. ដោយពិនិត្យហេតុផលនៃសេចក្តីសម្រេចបដិសេធ ដែលប្រកាន់យកដោយសហចៅក្រមស៊ើបអង្កេត និងដើម្បីធានាដល់ភាពយុត្តិធម៌នៃការជម្រះក្តីនេះ ក្រុមការពារក្តីសូមសំណូមពរដល់អង្គបុរេជំនុំជម្រះឲ្យរក្សាទុកជាប្រចាំនៅក្នុងស្មារតីនូវសិទ្ធិរបស់លោក ខៀវ សំផន និងកាតព្វកិច្ចរបស់ អ.វ.ត.ក។

### ក) សិទ្ធិរបស់ជនត្រូវចោទ

**ភាសានិងការបកប្រែ**

១៧. **មាត្រា ២៦.២ នៃ** “**កិច្ចព្រមព្រៀង**រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ” (តទៅនេះ “កិច្ចព្រមព្រៀង”) និង **មាត្រា ៤៥ ថ្មី នៃ** “ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ” (តទៅនេះ “ច្បាប់ អ.វ.ត.ក”) ដែលចែងថា “ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ និងអង្គបុរេជំនុំជម្រះ គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង”។

**គោលការណ៍នៃការបកស្រាយ**

១៨. **មាត្រា ១២.១ នៃកិច្ចព្រមព្រៀង** ចែងថា “នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា។ នៅពេលណាដែលច្បាប់កម្ពុជា មិនអាចដោះស្រាយបានចំពោះបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះ ទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។”

១៩. **មាត្រា ២១.១ នៃវិធានផ្ទៃក្នុងរបស់** អ.វ.ត.ក ចែងថា អត្ថបទត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនត្រូវចោទ ដើម្បីធានានូវអំពីសច្ចភាពផ្លូវច្បាប់ និង ដំណើរការនីតិវិធីប្រកបដោយតម្លាភាព ដោយគិតដល់លក្ខណៈពិសេសរបស់អង្គជំនុំជម្រះវិសាមញ្ញ។

**សិទ្ធិចំពោះសុវត្ថិភាព**

២០. ដោយអនុលោមតាមសច្ចធារណ៍នៃភាពគ្មានទោស **មាត្រា ២០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា**ចែងថា "ជាគោលការណ៍ ជនត្រូវចោទត្រូវតែនៅមានសេរីភាព។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្តោះអាសន្ន (...)"។

២១. **មាត្រា ៦៣.៣ នៃវិធានផ្ទៃក្នុង**របស់ អ.វ.ត.ក ចែងថា៖

"សហចៅក្រមស៊ើបអង្កេតអាចចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបាន តែក្នុងលក្ខខ័ណ្ឌដូចខាងក្រោម៖ ក) មានមូលហេតុដែលត្រូវបានរកឃើញ និង ជឿជាក់យ៉ាងច្បាស់ថាជននោះធ្លាប់បានប្រព្រឹត្តបទល្មើសមួយឬច្រើន ដូចមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ ហើយ ខ) សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការដ៏ចាំបាច់ (...)"។

២២. **មាត្រា ៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (PIDCP)** ដែលប្រទេសកម្ពុជាចូលជាសមាជិក ចាប់តាំងពីថ្ងៃទី២៦ ខែឧសភា ឆ្នាំ១៩៩២ ហើយដែលអាចអនុវត្តបានដោយផ្ទាល់នៅក្នុងច្បាប់ក្នុងប្រទេស[12] បញ្ជាក់បន្ថែមថា៖ "១. ជនគ្រប់រូប មានសិទ្ធមានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ គ្មានជនណាម្នាក់ ត្រូវចាប់ខ្លួន ឬ ឃុំខ្លួនតាមអំពើចិត្តបានឡើយ។ គ្មានជនណាម្នាក់ ត្រូវដកហូតសេរីភាពបានឡើយ លើកលែងតែមានហេតុផល និងស្របតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ (...) ៣. បុគ្គលណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់ឲ្យបំពេញមុខងារតុលាការ ក្នុងរយៈពេលយ៉ាងខ្លីបំផុត និង**ត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬត្រូវដោះលែង** (...) ៤. ជនណាដែលត្រូវដកហូតសេរីភាព ដោយការឃាត់ខ្លួន ឬឃុំខ្លួន ត្រូវមានសិទ្ធិដាក់ពាក្យបណ្តឹង ដើម្បីឲ្យតុលាការអាចសម្រេចដោយមិនពន្យារពេល អំពីនីត្យានុកូលភាពនៃការឃុំខ្លួន និងបង្គាប់ឲ្យនៅក្រៅឃុំ បើការឃុំខ្លួននោះមិនស្របច្បាប់។"

**សិទ្ធិរបស់ជនជាប់ចោទ និង សិទ្ធិទទួលបានការជម្រះក្តីប្រកបដោយភាពយុត្តិធម៌**

២៣. **មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញ**របស់ព្រះរាជាណាចក្រកម្ពុជា ចែងអំពីសិទ្ធិសម្រាប់ "គ្រប់បុគ្គល (...) ក្នុងការការពារខ្លួននៅចំពោះមុខតុលាការ"។

---

[12] សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧

២៤. មាត្រា ១៣.១ នៃកិច្ចព្រមព្រៀង មាត្រា ៣៥ ថ្មី នៃច្បាប់ អ.វ.ត.ក និង មាត្រា ២១ នៃវិធានផ្ទៃក្នុង កំណត់អំពីសិទ្ធិរបស់ជនជាប់ចោទ ដោយអនុលោមតាមមាត្រា ១៤ និង ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ (PIDCP)។ មាត្រា ៣៥ ថ្មី ចែងថា ជនជាប់ចោទមានសិទ្ធិស្មើៗគ្នា៖ ក/ ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បានអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន ខ/ មានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន និងទាក់ទងជាមួយមេធាវីខ្លួនដែលជ្រើសរើសដោយខ្លួនឯង គ/ ត្រូវបានទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ[13] ឃ/ ត្រូវបានជំនុំជម្រះដោយមានវត្តមានរបស់ជនសង្ស័យ និងការពារខ្លួនដោយខ្លួនឯង ឬតាមរយៈមេធាវីដែលជ្រើសរើសដោយខ្លួនឯង ត្រូវបានប្រាប់ឱ្យដឹងអំពីសិទ្ធិនេះ និងទទួលបានជំនួយផ្នែកច្បាប់ដោយឥតគិតថ្លៃ ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលដោយខ្លួនឯង ង/ ពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុក ក្នុងល័ក្ខខ័ណ្ឌដូចគ្នា នឹងភស្តុតាងដាក់បន្ទុកដែរ ច/ មានការជួយឧបត្ថម្ភដោយសេរីពីអ្នកបកប្រែភាសា ប្រសិនបើជនជាប់ចោទមិនយល់ ឬមិនអាចនិយាយបាននូវ ភាសាដែលប្រើនៅក្នុងតុលាការ (...)[14] ឆ/ មិនត្រូវបានគេបង្ខំឱ្យឆ្លើយប្រឆាំងនឹងខ្លួនឯង ឬបង្ខំឱ្យឆ្លើយសារភាពថា មានកំហុស។

## ខ) ករណីយកិច្ចរបស់អាជ្ញាធររដ្ឋ និងអាជ្ញាធរតុលាការ

### រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

២៥. មាត្រា ៣១ ចែងថា "ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្ស ដូចដែលបានកំណត់នៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ នៅក្នុងសេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្ស និងនៅក្នុងគ្រប់សន្ធិសញ្ញា និងអនុសញ្ញាដែលទាក់ទងនិងសិទ្ធិរបស់បុរស ស្ត្រី និងកុមារ"។ មាត្រា ១០៩ ចែងថា "អំណាចតុលាការ (...) ការពារសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋ។"

---

[13] សូមអានផងដែរទាក់ទងនឹងចំណុចនេះ មាត្រា ១៣.១ នៃកិច្ចព្រមព្រៀង

[14] សូមអានផងដែរទាក់ទងនឹងចំណុចនេះ មាត្រា ២៤ ថ្មី នៃ "ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក" ដែលចែងថា "ក្នុងដំណាក់កាលស៊ើបអង្កេត (...) [ជនសង្ស័យ] មានសិទ្ធិទទួលបាន នូវការបកប្រែចាំបាច់ជាភាសាដែលជនសង្ស័យនិយាយនិងយល់បាន"។ម្យ៉ាងទៀត មាត្រា ៣០ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ចែងថា "ក្នុងករណីចាំបាច់ សហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត និង អង្គជំនុំជម្រះត្រូវប្រើប្រាស់អ្នកបកប្រែ។ សាក្សី ឬ ភាគីអាចស្នើសុំអ្នកបកប្រែបានផងដែរ នៅពេលចាំបាច់ (...)"

**ធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ**

២៦. រដ្ឋនានាត្រូវជំរុញការគោរពជាសាកល និងការអនុវត្តសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ហើយដោយហេតុដូច្នេះ ត្រូវគោរពនិងអនុវត្តសិទ្ធិរបស់បុគ្គល ឬមនុស្ស។

**កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (PIDCP)**

២៧. មាត្រា **២** នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (PIDCP)៖ "១. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាគោរព និងធានាជូនបុគ្គលគ្រប់រូបដែលរស់នៅលើទឹកដី និងស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន នូវសិទ្ធិដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ដោយគ្មានការបែងចែកណាមួយ ជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាពដទៃៗទៀតឡើយ។ ២. បើមិនទាន់មានចែងក្នុងច្បាប់ដែលមានស្រាប់ ឬក្នុងវិធានការដទៃទៀតទេ រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យាចាត់វិធានការចាំបាច់ ស្របតាមនីតិវិធីនៃរដ្ឋធម្មនុញ្ញរបស់ខ្លួន និងស្របតាមបទបញ្ញត្តិទាំងឡាយនៃកតិកាសញ្ញានេះ ដោយសម្រួលដល់ការអនុម័តវិធានការច្បាប់ ឬវិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីធ្វើឱ្យសម្រេចបាននូវសិទ្ធិទាំងឡាយ ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ។ ៣. រដ្ឋភាគីនៃកតិកាសញ្ញានេះ សន្យា៖ ក) ធានាថា ជនណាដែលត្រូវគេរំលោភសិទ្ធិនិងសេរីភាពរបស់ខ្លួន ដែលទទួលស្គាល់ដោយកតិកាសញ្ញានេះ ជននោះមានសិទ្ធិឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ ទោះបីការរំលោភនោះបានប្រព្រឹត្តដោយជនដែលបំពេញមុខនាទីរាជការក៏ដោយ។ ខ) ធានាថា ជនណាដែលប្តឹងឱ្យមានការដោះស្រាយបែបនេះ ត្រូវមានសិទ្ធិឱ្យអាជ្ញាធរមានសមត្ថកិច្ចខាងយុត្តិធម៌ ខាងរដ្ឋបាល ឬខាងនីតិបញ្ញត្តិ ឬអាជ្ញាធរមានសមត្ថកិច្ចដទៃទៀតសម្រេចឱ្យខ្លួនដោយយោងតាមច្បាប់របស់រដ្ឋនោះ និងត្រូវបង្កើតលទ្ធភាពនៃការប្តឹងទៅតុលាការផង។ គ) ធានាថា អាជ្ញាធរមានសមត្ថកិច្ច ត្រូវអនុវត្តឱ្យបាននូវដំណោះស្រាយដែលបានសម្រេចហើយ។

## IV. មធ្យោបាយ

### ក) កង្វះមូលដ្ឋានច្បាប់សម្រាប់បដិសេធការបកប្រែទាំងស្រុងនៃឯកសារសំណុំរឿងរបស់

### លោក ខៀវ សំផន

២៨. ការបដិសេធការស្នើសុំបកប្រែរបស់លោក ខៀវ សំផន ឈរលើមូលដ្ឋានបទប្បញ្ញត្តិច្បាប់មិនតិចជាង ១២ នោះទេ[15]។ បទប្បញ្ញត្តិច្បាប់ទាំងនោះដែលបានរួមបញ្ចូលគ្នា ត្រូវបានបកស្រាយដោយយោងតាមយុត្តា-ធិការអន្តរជាតិដ៏សម្បូរណ៍បែប ទោះជាយុត្តាធិការនោះមិនអាចអនុវត្តបានចំពោះរឿងក្តីនេះក៏ដោយ។ ជាលទ្ធផល គឺមានការភ័ន្តច្រឡំដ៏ពិតប្រាកដ និងមាននីត្យានុកូលភាពតែលក្ខណៈខាងក្រៅដែលលាក់បំបាំងនូវមូលដ្ឋានគ្រឹះដ៏ពិតប្រាកដនៃសេចក្តីសម្រេចនោះ៖ គឺសេដ្ឋកិច្ចរបស់តុលាការ។

### ១) មានបទប្បញ្ញត្តិច្បាស់លាស់ទាក់ទងនឹងការបកប្រែ

២៩. តាមមាត្រា ២៦.២ នៃកិច្ចព្រមព្រៀង (ដែលមានចែងឡើងវិញនៅមាត្រា ៤៥ ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក)៖ "ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ គឺភាសាខ្មែរ ភាសាអង់គ្លេស និងភាសាបារាំង"។

៣០. ដោយមានលក្ខណៈជាសន្ធិសញ្ញា កិច្ចព្រមព្រៀងត្រូវធ្វើការបកស្រាយដោយអនុលោមតាមមាត្រា ៣១ (១) នៃអនុសញ្ញាទីក្រុងវីយែន ស្តីពីសិទ្ធិនៃសន្ធិសញ្ញាឆ្នាំ១៩៦៩ ដែលចែងថា "សន្ធិសញ្ញាត្រូវធ្វើការបកស្រាយដោយសុទ្ធចិត្ត ទៅតាមន័យធម្មតាដែលផ្តល់ដល់ពាក្យនៅក្នុងសន្ធិសញ្ញា នៅក្នុងបរិបទ និងទៅតាមកម្មវត្ថុ និងគោលដៅរបស់ខ្លួន។"

៣១. ទាក់ទងនឹងការបកប្រែ ការបកស្រាយបទប្បញ្ញត្តិនេះគឺមានភាពសាមញ្ញបំផុត៖ អ.វ.ត.ក មានភារកិច្ចដំណើរការនៅក្នុងភាសាបី គឺភាសាខ្មែរ ភាសាអង់គ្លេស និង ភាសាបារាំង។ ភាសាទាំងបីនេះមានតម្លៃដូចគ្នានិងតែមួយ គឺតម្លៃជាភាសាផ្លូវការ។ ដូច្នេះ ភាគីនីមួយៗត្រូវអាចធ្វើការងារនិងទំនាក់ទំនងគ្នា ដោយប្រើភាសាទាំងបីនេះ។ ការបកស្រាយនេះត្រូវបានបញ្ជាក់ដោយវិធាន ១២.៤ ក) នៃវិធានផ្ទៃក្នុង ដែលចែងថា មេធាវីបរទេសម្នាក់ត្រូវបានតែងតាំង ទាល់តែមេធាវីរូបនោះត្រូវ "ចេះនិយាយស្ទាត់ជំនាញ ភាសាខ្មែរ ភាសាបារាំង និង ភាសាអង់គ្លេស។"

### ២) ការបដិសេធការបកប្រែឯកសារសំណុំរឿង មិនបានគិតគូរដល់លក្ខណៈពិសេសរបស់ អ.វ.ត.ក

---

[15] នៃដីកាសម្រេច។

៣២. ទោះជាសហចៅក្រមស៊ើបអង្កេតលើកឡើងយ៉ាងច្បាស់នូវមាត្រា ៤៥ ថ្មី នៃច្បាប់ អ.វ.ត.ក ក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតពឹងផ្អែកជាសំខាន់លើយុត្តាធិការរបស់តុលាការអន្តរជាតិ ដើម្បីធ្វើការសន្និដ្ឋានថា គ្រប់ធាតុនៃភស្តុតាងមិនត្រូវធ្វើការបកប្រែទេ។ ទាក់ទងនឹងចំណុចជាច្រើន ថ្វីបើយុត្តាធិការអន្តរជាតិមានភាពសមហេតុផល ដើម្បីពន្យល់បំភ្លឺនូវបទប្បញ្ញត្តិដែលអាចអនុវត្តបាននៅក្នុង អ.វ.ត.ក.នោះ ទាក់ទងនឹងភស្តុតាងវិញ វាគឺជាការគ្រោះថ្នាក់ដែលពឹងផ្អែកទៅលើការចម្លងតាមហួសហេតុ។

៣៣. ពិតប្រាកដណាស់ អ.វ.ត.ក គឺជាតុលាការទីមួយដែលមានលក្ខណៈចម្រុះឬអន្តរជាតិ ដែលមិនមែនជាតុលាការដែលយកលំនាំតាមបែបអង់គ្លោសាក់សុង (anglo-saxonne) នោះទេ។ អ.វ.ត.ក ពឹងផ្អែកលើប្រពៃណីបែបរ៉ូម៉ាណូ-ហ្សែកម៉ានិច (romano-germanique) ដែលមានលក្ខណៈដឹកនាំដោយចៅក្រម ហើយដែលមានដំណាក់កាលស៊ើបអង្កេតពិសេសមួយ។ ប៉ុន្តែ ថ្វីបើសហចៅក្រមស៊ើបអង្កេតអះអាងថា "យកយុត្តាធិការខាងលើនេះមកកែតម្រូវ" ទៅតាមលក្ខណៈពិសេសរបស់ អ.វ.ត.ក ក៏ដោយ ក៏តាមការពិតទៅ សហចៅក្រមស៊ើបអង្កេតមានបំណងអនុវត្តនៅក្នុងដំណាក់កាលស៊ើបអង្កេត នូវការគិតគូរពិចារណាដែលយកផលចំណេញ នៅក្នុងប្រព័ន្ធនានាដែលមិនមានដំណាក់កាលនេះទេ។

៣៤. ជាការពិតណាស់ សេចក្តីសម្រេចរបស់តុលាការអន្តរជាតិដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេតធ្វើការបែងចែកដាច់ពីគ្នា ម្យ៉ាងរវាងអ្វីដែលបានជូនដំណឹង ដោយសហព្រះរាជអាជ្ញា ("discovery disclosure") ដែលជាអ្វីដែលមិនត្រូវធ្វើការបកប្រែ និងម្យ៉ាងទៀតនូវភស្តុតាងដែលបានដាក់តម្កល់នៅក្នុងពេលជម្រះក្តី ឬ សម្រាប់គាំទ្រកិច្ចចោទប្រកាន់ ដែលត្រូវធ្វើការបកប្រែ (សូមអានសេចក្តីសម្រេច *Delalic* ដែលបានលើកយកមកនិយាយ[16])។

៣៥. នៅក្នុងប្រព័ន្ធដែលយកលំនាំតាមបែបអង់គ្លោសាក់សុង (anglo-saxonne) ការពិភាក្សាអំពីភស្តុតាងធ្វើឡើងនៅក្នុងដំណាក់កាលរឿងក្តី ព្រោះថា មិនមានអ្វីជាសមមូលនៅដំណាក់កាលមុនការស៊ើបអង្កេតឡើយ។ ជាគោលការណ៍ ជនជាប់ចោទត្រូវបានចោទប្រកាន់តាំងពីពេលត្រូវបានចាប់ខ្លួន ហើយដូច្នេះ ជនជាប់ចោទមានសិទ្ធិទទួលបានការបកប្រែ នៅក្នុងភាសាដែលគាត់អាចយល់បាន នូវកិច្ចចោទប្រកាន់ ព្រមទាំងភស្តុតាងទាំងអស់ដែលកិច្ចចោទប្រកាន់នេះសម្អាងលើ និងតាំងពីគាត់ត្រូវបានចាប់ខ្លួនម្ល៉េះ។

---

[16] កថាខ័ណ្ឌ ខ ៣ និង ខ ៤ នៃដីកាសម្រេច

៣៦. នៅក្នុងប្រព័ន្ធច្បាប់រ៉ូម៉ាណូ-ហ្សែក្រម៉ានិច (romano-germanique) ជនត្រូវចោទស្គាល់អ្នកដាក់បន្ទុកប្រឆាំងនឹងខ្លួន និងភស្តុតាងគាំទ្រការដាក់បន្ទុកនោះ តែនៅពេលដែលមានដីកាដំណោះស្រាយតែប៉ុណ្ណោះ។ ប៉ុន្តែ នៅក្នុងដំណាក់កាលស៊ើបអង្កេតនិងដើម្បីធានានូវសិទ្ធិរបស់ក្រុមការពារក្តី ប្រព័ន្ធខាងលើនេះធានាដល់មេធាវីនូវសិទ្ធិទទួលបានឯកសារសំណុំរឿងស៊ើបអង្កេត នៅគ្រប់ពេលវេលា។ ហើយជាការសមហេតុផលបំផុត គឺនៅក្នុងភាសាដែលមេធាវីអាចយល់បាន។ ដោយហេតុដូច្នេះ ភាសាដែលមានសារប្រយោជន៍ គឺភាសារបស់មេធាវី ហើយមិនមែនជាភាសារបស់ជនជាប់ចោទនោះទេ[17]។

៣៧. នៅមុនមានដីកាដំណោះស្រាយ ឯកសារតែមួយគត់ដែលផ្តល់ព័ត៌មានដល់ក្រុមការពារក្តី អំពីការដាក់បន្ទុកប្រកបដោយសក្តានុពលប្រឆាំងនឹងកូនក្តីរបស់ខ្លួន គឺដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយដីកានេះគឺស្ថិតនៅក្នុងសំណុំរឿងទាំងស្រុង។ ប៉ុន្តែ ភស្តុតាងទាំងអស់នេះមិនអាចធ្វើការប្រៀបធៀបជាមួយ"discovery disclosure" ដែលជាលក្ខណៈពិសេសផ្ទាល់របស់ប្រព័ន្ធអង់គ្លេសាក់សុងបានទេ។ ជាការពិតណាស់ ឯកសារទាំងអស់នេះ ត្រូវបានយោងភ្ជាប់ទៅនឹងកំណត់សម្គាល់នៅផ្នែកខាងក្រោមទំព័រ នៅក្នុង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលជាអ្វីដែលបង្ហុលបង្ហាញយ៉ាងច្បាស់ថា សហព្រះរាជអាជ្ញាចាត់ទុកឯកសារទាំងនេះថាជាភស្តុតាងប្រកបដោយសក្តានុពល។ ហើសលើសពីនេះទៅទៀតនោះ ឯកសារទាំងនេះគឺស្ថិតនៅក្នុងសំណុំរឿងទាំងស្រុង។ ដូច្នេះ ជាបឋម គឺពិតជាអាចគ្រោងទុកបានថា ឯកសារទាំងនេះត្រូវបានប្រើប្រាស់នៅក្នុងពេលរឿងក្តី ដោយមិនចាំបាច់លើកឡើងអំពីឯកសារទាំងនេះ នៅក្នុងដីកាដំណោះស្រាយ។

៣៨. ក្រុមការពារក្តីបញ្ជាក់អះអាងថា ថ្វីបើមានទីត្បានុកូលភាពដែលមានតែសំបកក្រៅក៏ដោយ ក៏សេចក្តីសម្រេចសហចៅក្រមស៊ើបអង្កេត ឈរលើមូលដ្ឋាននៃការពិចារណាដែលមានលក្ខណៈជាក់ស្តែងសុទ្ធសាធ ហើយការពិចារណាទាំងនេះមិនបានស្គាល់អំពីកាតព្វកិច្ចរបស់ អ.វ.ត.ក ដែលត្រូវផ្តល់នូវការធានានូវសិទ្ធិរបស់លោក ខៀវ សំផន នោះទេ។

---

[17] សេចក្តីសម្រេចរបស់ តុលាការសិទ្ធិមនុស្សអឺរ៉ុប "CEDH" (Luedicke, Kamasinski, Klimentyev) ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត និងធ្វើឡើងនៅក្នុងរឿងក្តីដែលច្បាប់រ៉ូម៉ាណូ-ហ្សែក្រម៉ានិច (romano-germanique) ត្រូវបានយកមកអនុវត្តន៍ ហើយដែលមិនផ្ទុយនឹងការកត់សម្គាល់នេះទេ។ នៅក្នុងគ្រប់រឿងក្តីដែលបានលើកឡើង មេធាវីមានសិទ្ធិទទួលបានសំណុំរឿងនៅក្នុងភាសាដែលគាត់យល់ គឺភាសាប្រើប្រាស់នៅក្នុងការងាររបស់តុលាការដែលគាត់ប្រកបវិជ្ជាជីវៈ។

### ៣) ក្រុមការពារក្តីត្រូវទទួលបាននូវការធានាដ៏ពិតប្រាកដចំពោះសិទ្ធិរបស់ខ្លួន

៣៩. ជាការពិតប្រាកដណាស់ សហចៅក្រមស៊ើបអង្កេតទទួលស្គាល់ថា អវត្តមានការបកប្រែគឺអាចប៉ះពាល់ដល់គោលការណ៍នៃច្បាប់ប្រកបដោយភាពយុត្តិធម៌ និងដល់សិទ្ធិរបស់ក្រុមការពារក្តី ហើយសហចៅក្រមដឹងច្បាស់ថា សិទ្ធិទាំងនេះត្រូវតែអនុវត្តន៍[18]។ ផ្ទុយមកវិញ សហចៅក្រមស៊ើបអង្កេតបែរជាដាក់កំហិតដល់ជនត្រូវចោទ ឲ្យធានាឲ្យសិទ្ធិទាំងនោះត្រូវបានអនុវត្តដោយពិតប្រាកដទៅវិញ។

៤០. ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវនៃការបដិសេធការបកប្រែរបស់ខ្លួន និងដើម្បីបង្គាប់បញ្ជានូវវិធានការណ៍ជាបណ្តោះអាសន្នមួយចំនួន ជាការគួរឲ្យឆ្ងល់ដែលសហចៅក្រមស៊ើបអង្កេតពឹងផ្អែកលើសិទ្ធិរបស់ជនត្រូវចោទដែលត្រូវធ្វើការជម្រះក្តី នៅក្នុងរយៈពេលមួយសមស្រប។ តាមសហចៅក្រមស៊ើបអង្កេត ជនត្រូវចោទ (និងក្រុមការពារក្តីរបស់ខ្លួន) គួរតែកំណត់នូវភស្តុតាងដែលជនត្រូវចោទមានបំណងអនុវត្តន៍សិទ្ធិរបស់ខ្លួន និងធ្វើកិច្ចសហការប្រកបដោយឆន្ទៈស្លាបនា ចំពោះការដោះស្រាយបញ្ហាទាក់ទងនឹងការបកប្រែ។ បើមិនដូច្នេះទេ "វានឹងប៉ះពាល់ដល់សិទ្ធិរបស់ក្រុមការពារក្តី ជាអាទិ៍ដល់សិទ្ធិដែលត្រូវទទួលបានការជម្រះក្តី នៅក្នុងរយៈពេលមួយសមស្រប"[19]។

៤១. ទោះជាសហចៅក្រមស៊ើបអង្កេតនិយាយអំពីអ្វីក៏ដោយ ក៏វាមិនមានមូលដ្ឋានគ្រឹះផ្អែកច្បាប់ណាមួយដើម្បីនឹងដាក់កម្រិតកាតព្វកិច្ចបែបនេះ ដល់ក្រុមការពារក្តីនិងជនត្រូវចោទនោះទេ។ មាត្រា ២១ (៣) នៃកិច្ចព្រមព្រៀង និងវិធាន ១១ (៤) និង ២២ (១) នៃវិធានផ្ទៃក្នុង ដែលលើកឡើងដោយសហចៅក្រមស៊ើបអង្កេត មិនបានគ្រោងទុកនូវអ្វីមួយបែបនេះទេ[20]។

៤២. ជាការពិតប្រាកដណាស់ សហមេធាវីត្រូវគោរពតាមអត្ថបទច្បាប់ដែលអាចអនុវត្តន៍បាននៅក្នុង អ.វ.ត.ក ប៉ុន្តែពុំមានអ្វីមួយដែលតម្រូវឲ្យសហមេធាវីត្រូវ "សហការ" ជាមួយផ្នែករដ្ឋបាលនោះទេ! នេះគឺជាការបកស្រាយដោយរំលោភបំពានទៅលើអត្ថបទច្បាប់ ហើយពិតជាផ្ទុយទៅនឹង

---

[18] កថាខ័ណ្ឌ ក ៣ នៃដីកាសម្រេច

[19] កថាខ័ណ្ឌ ក ៤ នៃដីកាសម្រេច

[20] មាត្រា ២៣ (១) រំឮកអំពីករណីយកិច្ចរបស់មេធាវីដែលត្រូវគោរពចំពោះសិទ្ធិដែលអាចអនុវត្តន៍បាននៅចំពោះមុខ អ.វ.ត.ក និងអំពីក្រមសីលធម៌របស់ខ្លួន។ មាត្រា ១១ (៤) រំឮកអំពីលក្ខណៈវិនិច្ឆ័យនៃការចុះឈ្មោះរបស់មេធាវី ទៅក្នុងបញ្ជីរបស់អង្គភាពគាំពារការការពារក្តី។ មាត្រា ២២ (១) រំឮកអំពីសិទ្ធិរបស់ជនត្រូវចោទ ដែលទទួលបានជំនួយពីមេធាវីដែលខ្លួនបានជ្រើសរើស ជាមេធាវីជនជាតិខ្មែរ និង/ឬ មេធាវីបរទេស

ករណីយកិច្ចរបស់មេធាវី ដែលសីលធម៌តម្រូវឱ្យមាន "ភាពសម្ងាត់ផ្នែកវិជ្ជាជីវៈដាច់ខាត"។[21] បញ្ជូនទៅផ្នែកគ្រប់គ្រងតុលាការ (SAJ) (ទៅសហចៅក្រមស៊ើបអង្កេត[22] នៅក្នុងករណីមានជម្លោះ) នូវបញ្ជីឯកសារដែលខ្លួនយល់ថាមានភាពជាអាទិភាពសម្រាប់ក្រុមការពារក្តី ហើយដែលបន្ថែមពីលើបញ្ជីនោះ មាន "ហេតុផលនៃការស្នើសុំការបកប្រែ និងជាពិសេសនោះមានការបញ្ជាក់អំពីភាពត្រឹមត្រូវស្តីពីលំដាប់នៃអាទិភាព" បង្កើតបានជាការរំលោភបំពានយ៉ាងជាក់ច្បាស់ ទៅលើករណីយកិច្ចនេះ <u>"ព្រមទាំងជាការប៉ះពាល់ដល់ឯកសិទ្ធិនៃភាពមិនអាចរំលោភបំពានបានទៅលើគ្រប់ឯកសារទាំងអស់</u>" របស់មេធាវី[23]។

៤៣. លើសពីនេះទៅទៀតនោះ យុត្តាធិការដែលបានលើកឡើងរបស់គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប (តទៅនេះ "គណៈកម្មការEDH" មិនមានភាពសមហេតុផលនៅក្នុងករណីនេះទេ។ ជាការពិតណាស់ ប្រសិនបើ "អាកប្បកិរិយារបស់ភាគីធ្វើពាក្យបណ្តឹង"[24] អាចយកមកត្រិះរិះពិចារណាបានដើម្បីវាយតម្លៃចំពោះលក្ខណៈវិនិច្ឆ័យសមហេតុផលស្តីពីរយៈពេលនៃនីតិវិធីព្រហ្មទណ្ឌនោះ ទោះជានៅក្នុងករណីណាក៏ដោយ ក៏សិទ្ធិរបស់ភាគីដែលត្រូវធ្វើការជម្រះក្តីនៅក្នុងរយៈពេលមួយសមស្រប នឹងមិនអាចធ្វើឱ្យខ្លួនបាត់បង់នូវការអនុវត្តសិទ្ធិដទៃទៀត សម្រាប់រឿងក្តីប្រកបដោយភាពយុត្តិធម៌នោះទេ!

៤៤. តាមការពិត គឺ អ.វ.ត.ក ហើយមិនមែនលោក ខៀវ សំផន ទេ ដែលត្រូវធានាឱ្យមានការអនុវត្តដោយពិតប្រាកដនៃសិទ្ធិរបស់ខ្លួន។[25] <u>ការពារសិទ្ធិរបស់បុគ្គលទល់នឹងអំណាចរដ្ឋ គឺជាសារៈសំខាន់នៃច្បាប់អន្តរជាតិស្តីពីសិទ្ធិមនុស្ស ហើយរដ្ឋនានាត្រូវតែធ្វើអនុវត្តន៍</u>[26]។

---

[21] មាត្រា ៧ នៃក្រមសីលធម៌

[22] ហេតុផលនៃដីកាសម្រេច ចំណុច ៤

[23] មាត្រា ៤២ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក

[24] កថាខ័ណ្ឌ ៤៣ ដែលចែងនៅក្នុងសេចក្តីសម្រេច Frydelender c. ប្រទេសបារាំង ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០៖ "តុលាការ (...) សូមរំឭកថា រយៈពេល "សមហេតុផល" នៃនីតិវិធីមួយ ត្រូវធ្វើការវាយតម្លៃទៅតាមកាលៈទេសៈនៃបុព្វហេតុ និងដោយប្រើលក្ខណៈវិនិច្ឆ័យដូចតទៅនេះ៖ ភាពស្មុគស្មាញនៃរឿងក្តី អាកប្បកិរិយារបស់ភាគីធ្វើពាក្យបណ្តឹង និងអាកប្បកិរិយារបស់អាជ្ញាធរមានសមត្ថកិច្ច ព្រមទាំងស្ថានភាពនៃជម្លោះសម្រាប់សាម៉ីជន (សូមអានជាអាទិ៍ *Comingersoll S.A. c. Portugal* [GC], n° 35382/97, § 19, CEDH 2000-IV).

[25] ទាក់ទងនឹងចំណុចនេះ សូមអាន CEDH– Mathieu- Mohin c/ ប្រទេសបែលហ្ស៊ិច ថ្ងៃទី២ ខែមីនា ឆ្នាំ១៩៨៧ កឋាខ័ណ្ឌ ៥២

៤៥. ដោយអនុលោមតាមការពន្យល់បកស្រាយដែលធ្វើឡើងដោយគណៈកម្មាធិការសិទ្ធិមនុស្ស (CDH) រដ្ឋនានាមាន "កាតព្វកិច្ចទូទៅត្រូវគោរពសិទ្ធិដែលបានថ្លែងនៅក្នុងកតិកាសញ្ញា និងត្រូវធានានូវសិទ្ធិទាំងនេះ ចំពោះបុគ្គលគ្រប់រូប ដែលស្ថិតនៅលើទឹកដីខ្លួន និងដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន"។[27] កាតព្វកិច្ចនេះមិនទាក់ទងនឹងបុគ្គលទេ (លើកលែងតែនៅក្នុងកាលៈកាសៈដ៏តិចតួចបំផុតដែលមិនអនុវត្តន៍ចំពោះករណីនីមួយៗទេ) ហើយផ្ទុយមកវិញ បុគ្គលទាំងនេះគឺជាអ្នកកាន់កាប់សិទ្ធិដែលត្រូវបានធានាដូច្នេះ ហើយជាអ្នកទទួលបានការការពារនេះ[28]។

៤៦. ប៉ុន្តែ ការការពារខាងលើនេះទាក់ទងនឹងរដ្ឋទាំងមូល ហើយគណៈកម្មាធិការសិទ្ធិមនុស្ស (CDH) បញ្ជាក់ថា "កាតព្វកិច្ចដែលមាននៅក្នុងកតិកាសញ្ញាជាទូទៅ និងនៃមាត្រា ២ ជាពិសេស ដាក់កម្ហិតចំពោះរដ្ឋភាគីនីមួយៗនៅទូទាំងប្រទេស។ អាជ្ញាធរទាំងអស់របស់រដ្ឋ (អំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ) ព្រមទាំងអំណាចសាធារណៈ និងសមត្ថកិច្ចសាធារណៈដទៃទៀត នៅក្នុងគ្រប់លំដាប់ថ្នាក់ - ថ្នាក់ជាតិ តំបន់ ឬ មូលដ្ឋាន - គឺត្រូវចូលរួមដោយផ្ទាល់ នៅក្នុងភាពទទួលខុសត្រូវរបស់រដ្ឋភាគី"។[29] ការការពារនេះដាក់កម្ហិតជាពិសេសចំពោះ អ.វ.ត.ក ក្នុងនាមជាអង្គភាពតុលាការ[30]។

៤៧. ដូច្នេះ នៅក្នុងករណីនេះ ចៅក្រមរបស់ អ.វ.ត.ក សហព្រះរាជអាជ្ញា និង ការិយាល័យរដ្ឋបាលក្នុងឋានៈខ្លួនជា "អាជ្ញាធររបស់រដ្ឋ" គឺមានកាតព្វកិច្ចការពារនិងធានាចំពោះសិទ្ធិរបស់លោក ខៀវ សំផន គឺមិនធ្វើផ្ទុយពីនេះទេ!

៤៨. ពុំមែនព្រោះថា សហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការបកប្រែសំណុំរឿងព្រហ្មទណ្ឌប៉ះពាល់ដល់សិទ្ធិទទួលបានការកាត់ក្តីក្នុងរយៈពេលសមរម្យ ដែលរដ្ឋ និងអាជ្ញាធរដែលតំណាងត្រូវរួចផុតពីកាតព្វកិច្ចរបស់ខ្លួន។ អាជ្ញាធររដ្ឋមាន"កាតព្វកិច្ចដ៏ងលី"ជាពិសេសក្នុងដំណើរការ

---

[26] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាច្រកកម្ពុជា និង មាត្រា ២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ

[27] កំណត់សម្គាល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្ស លេខ ៣១ "ប្រភេទនៃកាតព្វកិច្ចច្បាប់ទូទៅ ដែលដាក់កម្ហិតដល់រដ្ឋភាគី ចំពោះកតិកាសញ្ញា (សម័យប្រជុំលើកទី ៨០) U.N. Doc. HRI/GEN/1/Rev. 7 (2004), កថាខ័ណ្ឌ ៣

[28] ដូចឯកសារខាងលើនេះ កថាខ័ណ្ឌ ៣

[29] ដូចឯកសារខាងលើនេះ កថាខ័ណ្ឌ ៤

[30] មាត្រា ១០៩ នៃរដ្ឋធម្មនុញ្ញ

ចោទប្រកាន់ ដោយហេតុថាជនត្រូវចោទស្ថិតក្នុងការឃុំខ្លួនបណ្ដោះអាសន្ន[31]។ ក្នុងករណីនេះ ពួកគេពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនឡើយ។

៤៩. ជាដំបូង តម្រូវការនៃការបកប្រែពុំត្រូវបានវាយតម្លៃជាដំបូងដោយភាគីហត្ថលេខីនៃលក្ខន្តិកៈ អ.វ.ត.កឡើយ។ ដូច្នោះថវិការរបស់អ.វ.ត.កពុំបានគិតលើទ្រង់ទ្រាយជាសំខាន់នៃនីតិវិធី ហើយ ការិយាល័យរដ្ឋបាលពុំមានមធ្យោបាយហិរញ្ញវត្ថុ ឬធានធានមនុស្ស សម្រាប់បកប្រែសំណុំរឿង ព្រហ្មទណ្ឌឡើយ[32]។

៥០. បន្ទាប់មកទៀត សហព្រះរាជអាជ្ញាបានសម្រេចដាក់ឯកសារចំនួនជាង៦០ ០០០ទំព័រ ជាការគាំទ្រ ដល់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់ខ្លួន។ភាគីការពារក្ដីសូមគាំទ្រថាវាគួរតែផ្សេងពីនេះ។ យើងមានសិទ្ធិពិចារណាពីអ្វីដែលអាចកើតឡើងថា បើសហព្រះរាជអាជ្ញាសម្រេចថានឹងមិនផ្អែក លើឯកសារភស្តុតាងចំនួន១៣៥កម្រងឯកសារ(classeurs) ដែលតាមពិត នេះជាការពិតតែបែរ ជាផ្អែកលើឯកសារចំនួន២ កម្រងឯកសារ(classeurs)វិញ ដែលសុទ្ធជាភស្តុតាងជ្រើសរើស ជាសារវន្ត និងដែលមានតម្លៃគតិយុត្តិ។ គ្មាននរណាម្នាក់អាចគិតដល់មិនឲ្យភាគីក្នុងការបកប្រែ ឯកសារទាំងនោះឡើយ! ដូច្នេះ វាពិតជាអាចទៅរួច ក្នុងការរៀបចំបកប្រែឯកសារថ្មីៗ ដែលបាន ដាក់បញ្ចូលក្នុងសំណុំរឿងជាបន្តបន្ទាប់នៃនីតិវិធី និងដើម្បីបំពេញតាមតម្រូវការនៃរយៈពេលសម ស្រប។

៥១. ជាចុងក្រោយ ក្នុងនាមជាអាជ្ញាធររដ្ឋ តែក៏ជាអង្គការទទួលបន្ទុកឆ្លើយតបយ៉ាងឆាប់រហ័សទៅនឹង សំណើសុំផ្សេងៗរបស់ជនត្រូវចោទ[33]ក្នុងអម្លុងពេលស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតបាន ស្ថិតក្នុងភាពស្ងៀមស្ងាត់អស់ជាច្រើនខែលើបញ្ហាបកប្រែ និងបានដាក់លោក ខៀវ សំផន ក្នុង ស្ថានភាពមួយក្រៅច្បាប់។

៥២. នៅទីបំផុត គ្មានអាជ្ញាធររដ្ឋណាមួយដែលទទួលបន្ទុកការធានាសិទ្ធិរបស់លោក ខៀវ សំផន បាន បំពេញការយកចិត្តទុកដាក់ដោយម៉ត់ចត់ដោយផ្ទាល់ ដើម្បីបំពេញសិទ្ធិរបស់គាត់ ដែលត្រូវទទួល

---

[31]សូមមើលចំណុចនេះ គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប Tomasi តទល់នឹងបារាំងថ្ងៃទី២៧ សីហា ១៩៩២ កថាខណ្ឌ៨៤។

[32] សូមមើលរបាយការណ៍របស់អង្គភាពគ្រប់គ្រងតុលាការលើការបកប្រែ ថ្ងៃទី៣០ មិថុនា ២០០៨ ឯកសារ A190-III។

[33] មាត្រា ១៣៣ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា និងវិធាន ៥៥-១០នៃវិធានផ្ទៃក្នុង។

បានការជម្រះក្តីនៅក្នុងរយៈពេលមួយសមស្របនោះទេ។ ផ្ទុយមកវិញ អាជ្ញាធររដ្ឋទាំងបីនេះគឺជាអ្នកទទួលខុសត្រូវរួមគ្នា៖ ពិតប្រាកដណាស់ គណៈកម្មាធិការសិទ្ធិមនុស្ស (CDH) បានបញ្ជាក់អះអាងយ៉ាងច្បាស់ថា គ្មានអាជ្ញាធរណាមួយអាច "ផ្តល់ទឡ្ហីករណ៍ទេ ដោយហេតុថា សកម្មភាពមួយដែលមិនទាក់ទងនឹងបទប្បញ្ញត្តិនៃកតិកាសញ្ញា បានត្រូវអនុវត្តន៍ដោយអាជ្ញាធរមួយផ្សេងទៀតរបស់រដ្ឋ នៅក្នុងបំណងធ្វើឱ្យរដ្ឋភាគីរួចផុតពីភាពទទួលខុសត្រូវនៃសកម្មភាពនេះ និងរួចផុតពីវិសមភាពដែលបណ្តាលមកពីសកម្មភាពនេះ។"[34]

៥៣. លើសពីនេះទៅទៀត "ការមិនគោរពតាមកាតព្វកិច្ចនេះ មិនអាចបញ្ជាក់ហេតុផលដោយការពិនិត្យពិចារណាផ្នែកនយោបាយ ផ្នែកសង្គម វប្បធម៌ ឬ សេដ្ឋកិច្ចនៅក្នុងប្រទេសបានទេ"។[35] ជាឧទាហរណ៍ ទោះជានៅក្នុងករណីណាក៏ដោយ អាជ្ញាធរមិនអាចឈរលើមូលដ្ឋាននៃការពិចារណាផ្នែកថវិកា ឬ លើកង្វះខាតផ្នែកសម្ភារៈបរិក្ខារឬបុគ្គលិក ដើម្បីបញ្ជាក់ហេតុផលចំពោះការរំលោភសិទ្ធិរបស់ជនត្រូវចោទទេ។[36]

៥៤. ដោយបញ្ជាក់ហេតុផលនៃការបដិសេធការបកប្រែឯកសារសំណុំរឿងលោក ខៀវ សំផន ដោយពឹងផ្អែកលើ "ការគិតគូរពិចារណាទៅលើបញ្ហាសេដ្ឋកិច្ចរបស់តុលាការ(...) បន្ទុកការងារនិងធនធានស្ដួចស្ដើងរបស់អ.វ.ត.កទាក់ទងនឹងការបកប្រែ"[37]នោះ សហចៅក្រមស៊ើបអង្កេតបានធ្វើឱ្យសេចក្ដីសម្រេចរបស់ខ្លួនខ្វះនូវមូលដ្ឋានច្បាប់។

## ខ) អវត្តមាននៃការបកប្រែ និងវិធានការចាត់ដោយសហចៅក្រមស៊ើបអង្កេត

---

[34] ដូចឯកសារខាងលើនេះ នៅក្នុងកំណត់សម្គាល់ផ្នែកខាងក្រោមទំព័រ ២៧ កថាខ័ណ្ឌ ៤

[35] ដូចឯកសារខាងលើនេះ កថាខ័ណ្ឌ ៤។ លើសពីនេះទៅទៀត រដ្ឋចុះកិច្ចសន្យាត្រូវ "ធ្វើការរៀបចំប្រព័ន្ធតុលាការរបស់ខ្លួន ដោយធ្វើយ៉ាងណាឱ្យយុត្តាធិការរបស់ខ្លួន អាចធានាដល់ម្នាក់ៗ នូវសិទ្ធិទទួលបានសេចក្ដីសម្រេចជាស្ថាពរ (...) នៅក្នុងរយៈពេលមួយសមស្រប។" CEDH Frydlender c. ប្រទេសបារាំង សេចក្ដីសម្រេចចុះថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០០ កថាខ័ណ្ឌ ៤៥

[36] ត្រង់ចំណុចនេះ សូមអាន CEDH- សេចក្ដីជូនដំណឹង លេខ ៣៣៦/១៩៨៨ André Fillastre និង Pierre Bizouarn ទល់នឹងប្រទេសបូលីវី (Bolive) ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៨៨ កថាខ័ណ្ឌ ៦.៥ - ហើយនៅក្នុងគំនិតដដែលនេះ សូមអាន Mattocia c/ប្រទេសអ៊ីតាលី ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០០ កថាខ័ណ្ឌ ៨0 - CEDH។ Eckle c. ប្រទេសអាល្លឺម៉ង់ កថាខ័ណ្ឌ ៨៥ និង កថាខ័ណ្ឌ ៩២

[37] ដីកាសម្រេច កថាខ័ណ្ឌ ក ៥ និង ង ១ កថាខ័ណ្ឌ - សូមអានផងដែរ របាយការណ៍របស់ផ្នែកគ្រប់គ្រងតុលាការស្ដីពីការបកប្រែ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៨ A190-III

## ប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិរបស់លោក ខៀវ សំផន

៥៥. ផ្ទុយនឹងអ្វីដែលសហចៅក្រមស៊ើបអង្កេតបានព្យាយាមបញ្ជាក់ ការរំលោភទៅលើសិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយភាពយុត្តិធម៌ របស់លោក ខៀវ សំផន មិនមកពីអកប្បកិរិយារបស់គាត់ទេ ប៉ុន្តែបណ្តាលមកពីការដែល អ.វ.ត.ក. មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការចាត់ការនីតិវិធីឲ្យបានលឿន និងត្រឹមត្រូវ។ លទ្ធផលគឺការរំលោភសិទ្ធិរបស់លោក ខៀវ សំផន យ៉ាងធ្ងន់ធ្ងរ។

### ១) ការរំលោភសិទ្ធិរបស់លោក ខៀវ សំផន ទទួលបាននូវជំនួយរបស់មេធាវី

៥៦. មាត្រា៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជាចែងថា ៖ "នៅក្នុងការចោទប្រកាន់មកលើខ្លួន ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បបរមា និងស្មើៗគ្នា (...) ឲ្យមានមេធាវីដែលជ្រើសរើសដោយខ្លួនឯង (...)"។ ម្យ៉ាងទៀត វិធាន២២.១ នៃវិធានផ្ទៃក្នុង ក៏ផ្តល់លទ្ធភាពឲ្យគាត់ទទួលបាននូវ "ជំនួយពីមេធាវីជាតិ ឬមេធាវីអន្តរជាតិដោយសហការជាមួយមេធាវីជាតិ"។

៥៧. នៅចំពោះមុខ អ.វ.ត.ក. វិធាននេះមិនមែនគ្មានសារៈសំខាន់ទេ។ ភាពពិសេសនៃអង្គជំនុំជម្រះនោះគឺភាពចម្រុះរបស់អង្គជំនុំជម្រះនេះហើយ។ គោលដៅនៃភាពចម្រុះនេះ គឺធានាឲ្យមាននីតិវិធីមួយប្រកបដោយយុត្តិធម៌ និងធានាគោរពធ្វើតាមបទដ្ឋានអន្តរជាតិ ដោយរក្សានូវអធិបតេយ្យភាពនៃប្រទេសកម្ពុជានៅក្នុងការជំនុំជម្រះដែលកំពុងដំណើរការ។ វិធាននេះត្រូវបានអនុវត្តមែន នៅក្នុងការិយាល័យសហព្រះរាជអាជ្ញា[38] ហើយវិធាននេះត្រូវបានគោរពក្នុងការចាត់តាំងចៅក្រម[39]ផងដែរ។ ការអនុវត្តចំពោះក្រុមការពារក្តី មិនអាចខុសពីការអនុវត្តយ៉ាងនេះទេ ៖ លោក ខៀវ សំផន មានសិទ្ធិទទួលបាននូវជំនួយពេញលេញ និងទាំងស្រុងពីសំណាក់មេធាវីពីរនាក់របស់ខ្លួន ហើយលោកក៏មានសិទ្ធិទទួលនូវអត្ថប្រយោជន៍នៃការពិគ្រោះការងារគ្នារបស់ពួកគាត់ដែរ។

៥៨. ជាការជាក់ស្តែងនេះ លោក ខៀវ សំផន បានជ្រើសរើសមេធាវីពីរនាក់ គឺសហមេធាវីខ្មែរម្នាក់ និងសហមេធាវីអន្តរជាតិជនជាតិបារាំងម្នាក់។ មេធាវីពីរនាក់នេះត្រូវតែមានលទ្ធភាពធ្វើការជាមួយគ្នា

[38] សូមអាន ជាអាទិ៍ មាត្រា៦នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក. និងមាត្រាទី១៦ នៃច្បាប់ស្តីពីការបង្កើតនៃ អ.វ.ត.ក ។

[39] ចំណែកឯសហចៅក្រមស៊ើបអង្កេតវិញ សូមអាន មាត្រា៥នៃកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក. និងមាត្រា២៣ នៃច្បាប់ស្តីពីការបង្កើតនៃ អ.វ.ត.ក ។

ទោះបីពួកគាត់មិនមែនជាអ្នកធ្វើសហការឬគ្មានឋានៈជាចៅក្រម និងកូនចៅក៏ដោយ។ នៅពេលសវនាការ ទាំងពីរនាក់ត្រូវមានវត្តមាន ហើយមេធាវីម្នាក់មិនអាចជំនួសមេធាវីម្នាក់ទៀតបានទេ។

៥៩. មេធាវីទាំងពីរនាក់មានកាតព្វកិច្ចផ្តល់នូវជំនួយពិតប្រាកដឱ្យកូនក្តីរបស់ខ្លួន[40]។ បើយោងតាមក្រមសីលធម៌ មេធាវីដែលបានចុះក្នុងបញ្ជីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវតែ "កំណត់ឱ្យបានច្បាស់តាមសម្បជញ្ញៈរបស់ខ្លួន នូវកត្តាចាំបាច់សម្រាប់ធ្វើការការពារ"[41]។ លើសពីនេះទៅទៀត មេធាវីមានសិទ្ធិ "ទទួលបានច្បាប់ចម្លងនៃសំណុំរឿង ឬ កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធី និងយកឯកសារនេះ រួមជាមួយឯកសារដែលពាក់ព័ន្ធដទៃទៀត ដើម្បីពិភាក្សាជាមួយកូនក្តីរបស់ខ្លួន" ហើយក៏មានសិទ្ធិ "គ្រប់ពេលវេលាក្នុងការពិនិត្យ និងថតចម្លងសំណុំរឿង [ស៊ើបអង្កេត]"[42]។

៦០. លោក VERGÈS គ្មានលទ្ធភាពក្នុងការពិនិត្យឯកសារពីសំណុំរឿងជាភាសាមួយដែលគាត់យល់បាន។ ដូច្នេះហើយគាត់មិនអាចចូលរួមការពារកូនក្តីរបស់គាត់ទេ។ ជាលទ្ធផល លោក ខៀវ សំផន បានបាត់បង់សិទ្ធិរបស់គាត់ក្នុងការទទួលបាននូវជំនួយពីសំណាក់សហមេធាវីរបស់គាត់។

### ២) ការរំលោភលើសិទ្ធិចូលរួមក្នុងនីតិវិធី

៦១. មាត្រា៣៥ថ្មីនៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក. និងវិធាន២១នៃវិធានផ្ទៃក្នុង ចែងថា ៖ ជនត្រូវចោទមានសិទ្ធិ "ស្មើៗគ្នា (...) ទទួលព័ត៌មានភ្លាមៗ និងលម្អិតជាភាសាដែលខ្លួនយល់បាន អំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់ចំពោះខ្លួន (...) មានសិទ្ធិពិនិត្យភស្តុតាងដាក់បន្ទុក និងទទួលបាននូវការចូលរួម និងការពិនិត្យភស្តុតាងដោះបន្ទុក ក្នុងល័ក្ខខ័ណ្ឌដូចគ្នានឹងភស្តុតាងដាក់បន្ទុកដែរ (...) ហើយមានសិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ ដើម្បីរៀបចំការពារខ្លួន"។ មាត្រា១៤.១ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ក៏ចែងផងដែរថា ៖ "ជនគ្រប់រូបត្រូវមានភាពស្មើគ្នានៅចំពោះមុខតុលាការ និងសាលាជម្រះក្តី"។

---

[40] គណៈកម្មាធិការសិទ្ធិមនុស្ស - Pinto c/ Trinidad et Tobago, លេខ២៣២/ឆ្នាំ១៩៨៧; Kelly c/ Jamaïque លេខ២៥៣/ឆ្នាំ១៩៨៧។

[41] មាត្រា៧នៃក្រមសីលធម៌ ។

[42] វិធាន៥៥.៦ និង ២២.៣ នៃវិធានផ្ទៃក្នុង ។

៦២. ការដែលសហចៅក្រមស៊ើបអង្កេតស្នើឱ្យជនត្រូវចោទជ្រើសរើសឯកសារខ្លះសំរាប់ការបកប្រែ សហចៅក្រមស៊ើបអង្កេតបានជំរុញជនត្រូវចោទជ្រើសរើសភស្តុតាងដែលពួកគាត់នឹងយកមកធ្វើជាសំអាង ក្នុងការស្វែងរកការពិត ដែលជាកាតព្វកិច្ចរបស់ខ្លួន។ សហចៅក្រមស៊ើបអង្កេត គឺជាអ្នកដែលត្រូវដឹកនាំការស៊ើបអង្កេត។ មានតែពួកគាត់ទេដែលអាច "ចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិត" ហើយពួកគាត់ក៏"ត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះ ជាភស្តុតាងដាក់បន្ទុក ឬដោះបន្ទុកក៏ដោយ"[43]។ នៅពេលដែលសហចៅក្រមស៊ើបអង្កេតប្រគល់អំណាចឱ្យភាគីក្នុងការជ្រើសរើសភស្តុតាងដែលភាគីយល់ថាជាភស្តុតាងសំខាន់យ៉ាងដូច្នេះ សហចៅក្រមស៊ើបអង្កេតលះបង់កាតព្វកិច្ចរបស់ខ្លួននេះ ហើយដកសិទ្ធិរបស់លោក ខៀវ សំផន ក្នុងការចូលរួមយ៉ាងពិតប្រាកដក្នុងនីតិវិធីស៊ើបអង្កេត។

៦៣. ជាការពិត គ្មានអ្វីដែលអាចធានាថា សហចៅក្រមស៊ើបអង្កេតនឹងធ្វើបច្ចុប្បន្នកម្ម ហើយនឹងធ្វើការពិនិត្យទៅលើភស្តុតាងដោះបន្ទុកទាំងអស់ដែលមាននៅក្នុងសំណុំរឿងស៊ើបអង្កេតនោះទេ ក៏ដូចគ្មានអ្វីដែលអាចធានាថា លោក ខៀវ សំផន នឹងមានពេលវេលាពិតប្រាកដ ដើម្បីរៀបចំការការពារខ្លួនប្រឆាំងនឹងភស្តុតាងដែលនឹងលេចឡើងជាបន្តបន្ទាប់ទៅតាមដំណាក់កាលនៃការបកប្រែ។

៦៤. លើសពីនេះទៅទៀត វិធានការទាំងនោះមិនអាចធានាឱ្យមានសមភាពនៃមធ្យោបាយតទល់គ្នាទេ។ បើតាមគណៈកម្មាធិការសិទ្ធិមនុស្ស[44] និងគណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប(ECHR)[45] សមភាពនៃមធ្យោបាយតទល់គ្នា គឺជាគោលការណ៍មួយដែលមានបំណងធានាថា ភាគីមួយអាចបង្ហាញភស្តុតាងរបស់ខ្លួនក្នុងស្ថានភាពដូចគ្នានឹងស្ថានភាពរបស់ភាគីម្ខាងទៀតដែរ។ គោលការណ៍សមភាពនៃមធ្យោបាយតទល់គ្នានេះ "[ក៏] តម្រូវឱ្យចៅក្រមធានាកុំឱ្យភាគីណាមួយស្ថិតនៅក្នុង

[43] វិធាន៥៥.៥នៃវិធានផ្ទៃក្នុង ។

[44] តាមគណៈកម្មាធិការសិទ្ធិមនុស្ស Franck Robinson តទល់នឹង Jamaique Communication lex 223/1987, UN Doc. CCPR/C/35/D/223/1987 (1989)។

[45] Dombo Beheer B.V. c/ Les Pays Bas (ស៊ីវិល) គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប (CEDH) សាលក្រមចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ១៩៩៣ កថាខ័ណ្ឌ៣៣ ។ Bullut តទល់នឹង ប្រទេសអូទ្រីស គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប (CEDH) សាលក្រមចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៩៦ កថាខ័ណ្ឌ៤៧ ។

ស្ថានភាពមួយដែលមិនស្មើនឹងភាគីមួយទៀត ក្នុងការបង្ហាញពីសេចក្តីសំអាងរបស់ខ្លួន"[46] (ការបកប្រែក្រៅផ្លូវការ)។

៦៥. ដោយឡែក ក្នុងករណីនេះ លោកខៀវ សំផន ស្ថិតនៅក្នុងស្ថានភាពមួយដែលមិនស្មើនឹងភាគីដាក់បន្ទុក ហើយស្ថានភាពនេះបានកើតឡើងតាំងពីការចាប់ផ្តើមនៃការស៊ើបសួរ ៖ ទីមួយ សហព្រះរាជអាជ្ញាបានមានពេលវេលាច្រើនដើម្បីបញ្ចូលភស្តុតាង (ដាក់បន្ទុក) រាប់ពាន់ឯកសារក្នុងសំណុំរឿង ទោះបីជានៅពេលដដែលនោះ ក្រុមការពារក្តីត្រូវបានស្នើសុំឱ្យបញ្ចូលតែ "សម្រង់" ប៉ុណ្ណោះ និងកុំឱ្យរារាំងល្បឿននៃនីតិវិធីចោទប្រកាន់។ ទីពីរ លោក ខៀវ សំផន បានជ្រើសរើសភាសាបារាំងជាភាសាទីពីរប្រើក្នុងក្របខ័ណ្ឌការងារ[47]ហើយឯកសារភាគច្រើនដែលបានផ្តល់ជាភាសាផ្សេងពីភាសាខ្មែរ គឺជាឯកសារភាសាអង់គ្លេស[48] ដែលភាសានេះជាភាសាទីពីរប្រើក្នុងក្របខ័ណ្ឌការងាររបស់សហព្រះរាជអាជ្ញា។ ដូច្នេះហើយ សហព្រះរាជអាជ្ញាអាចពិនិត្យបានឯកសាររាប់រយច្បាប់ ដែលសហមេធាវីការពារក្តីមិនអាចមើលយល់បានឡើយ។

៦៦. ម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេតគ្មានសមត្ថកិច្ចបង្ខំសហមេធាវីការពារក្តីឱ្យចាត់ការយ៉ាងនេះ ឬយ៉ាងនោះ ក្នុងការរៀបចំការងារការពារក្តីរបស់ខ្លួន។ វិធានការដែលសហចៅក្រមស៊ើបអង្កេតលើកឡើងនោះ គឺជាការជ្រៀតជ្រែក ដែលមិនអាចអត់ឱនបានរបស់សហចៅក្រមស៊ើបអង្កេត ក្នុងការងាររបស់ក្រុមការពារក្តី ដែលគ្មានអ្វីអាចដោះសារបានឡើយ ហើយដែលប៉ះពាល់ដល់សិទ្ធិសេរីភាពយ៉ាងខ្លាំងផងដែរ។ ថ្ងៃនេះ ក្នុងនាមសិទ្ធិទទួលការជំនុំជម្រះក្នុងរយៈពេលសមរម្យ សហចៅក្រមស៊ើបអង្កេតបានសម្រេចថា ក្រុមការពារក្តីអាចពិនិត្យបានតែឯកសារនៃសំណុំរឿងរបស់ខ្លួនមួយភាគជាភាសាមួយ ដែលភាសានេះជាភាសាផ្លូវការមួយដែរ។ សហចៅក្រមស៊ើបអង្កេតក៏បានសំរេចផងដែរថា សហមេធាវីប្រព្រឹត្តយ៉ាងដូចម្តេចដើម្បីធានាការគោរពសិទ្ធិកូនក្តីរបស់ខ្លួន។

---

[46] តុលាការព្រហ្មទណ្ឌអន្តរជាតិសំរាប់អតីតប្រទេសយូហ្គូស្លាវី សាលដីកានៃសាលាឧទ្ធរណ៍ រឿងក្តី រដ្ឋអាជ្ញា c/ Duscko Tadic ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខ័ណ្ឌទី៤៨ ដែលដកស្រង់ពីសាលដីកានៃគណៈកម្មាធិការសិទ្ធិមនុស្សអឺរ៉ុប Kaufman c/ Belgique, Dombo Beheer B.V. c/ Pays-Bas និងសាលដីកានៃតុលាការសិទ្ធិមនុស្សអឺរ៉ុប(ECHR) ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៩៣ / Delcourt c/ Belgique ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ១៩៧០។ សូមក៏អានដែរ តុលាការសិទ្ធិមនុស្សអឺរ៉ុប សាលដីកា Stuppat c/ RFA អំពីគោលការណ៍នេះ។

[47] មាត្រា ២(២) នៃសេចក្តីណែនាំអនុវត្ត ។

[48] ជាអាទិ៍ នៅក្នុងស្រោមតម្រៀបលិខិត១២៣ក្បាលនៃភស្តុតាងផ្តល់ដោយសហព្រះរាជអាជ្ញា ក្នុងការគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មាន ៣២១៤៥ ឯកសារជាភាសាខ្មែរ ៥១៧៨ ឯកសារជាភាសាអង់គ្លេស និងមានតែ ១៥៨២ ឯកសារជាភាសាបារាំងទេ ។ សូមអាន ឧបសម្ព័ន្ធទី១ ។

នៅថ្ងៃស្អែក តើសហចៅក្រមស៊ើបអង្កេតនឹងសំរេចអ្វីទៀត ? តើសហចៅក្រមស៊ើបអង្កេតនឹងសម្រេចទៀតថា ជនត្រូវចោទគ្មានសិទ្ធិសុំឱ្យមានកិច្ចស៊ើបសួរទៀតឡើយ ពីព្រោះត្រូវតែធានាឱ្យគោរព "សិទ្ធិទទួលការជំនុំជម្រះក្នុងរយៈពេលសមស្រប" ទេដឹង ? អ្នកណាក៏មិនអាចគ្រងទុកជាមុនបានទេ។

### ៣) ការរំលោភលើសិទ្ធិទទួលបាននូវការជំនុំជម្រះក្នុងរយៈពេលមួយសមស្រប

៦៧. ទោះជាសហចៅក្រមស៊ើបអង្កេតអះអាងថាម៉េចក៏ដោយ ក៏អវត្តមាននៃការបកប្រែនៃសំណុំរឿងព្រហ្មទណ្ឌនេះហើយ ដែលបង្កឱ្យមានការយឺតយ៉ាវក្នុងនីតិវិធី ហើយការយឺតយ៉ាវនេះមិនមែនបណ្តាលមកពីការដែលក្រុមការពារក្តីសុំឱ្យមានការបកប្រែនេះទេ។

៦៨. មាត្រា ៣៥ថ្មី (គ) នៃច្បាប់ស្តីពីការបង្កើតនៃ អ.វ.ត.ក. ធានាឱ្យជនត្រូវចោទមានសិទ្ធិទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ ដោយអនុលោមតាមមាត្រា១៤នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ហើយសិទ្ធិនេះក៏ចែងនៅក្នុងមាត្រា៦(១)នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប (ECHR) ផងដែរ)។ លំអិតជាងនេះទៅទៀត មាត្រា៩.៣នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ចែងថា "ជនណាដែលបានចាប់ខ្លួន ឬឃុំខ្លួនពីបទព្រហ្មទណ្ឌ នឹងត្រូវបាននាំខ្លួនទៅចំពោះមុខចៅក្រម ឬអាជ្ញាធរណាមួយទៀត ដែលអនុញ្ញាតដោយច្បាប់ឱ្យបំពេញមុខងារតុលាការក្នុងរយៈពេលយ៉ាងខ្លីបំផុត និតត្រូវបានជំនុំជម្រះក្នុងរយៈពេលសមស្រប ឬក៏ត្រូវដោះលែង"។ បទបញ្ញត្តិនេះក៏មានចែងនៅក្នុងមាត្រា៥(៣)នៃអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប (ECHR) ផងដែរ[49]។

៦៩. ច្បាប់ សិទ្ធិមនុស្សអន្តរជាតិបង្ខំឱ្យមានវិធីពីរយ៉ាង ដើម្បីធានាឱ្យការជំនុំជម្រះប្រព្រឹត្ត ក្នុងរយៈពេលសមស្របយ៉ាងពិតប្រាកដ ហើយវិធីពីរនេះមានគោលដៅដោយឡែកពីគ្នា។ បើតាមគណៈកម្មាធិការសិទ្ធិមនុស្ស ការការពារដូចមានចែងនៅក្នុងមាត្រា៩ មានបំណងធានាឱ្យ"ការឃុំឃាំង [នៅជា]ករណីលើកលែង ហើយត្រូវមានរយៈពេលខ្លីតាមតែអាចទៅបាន"។ នេះគឺជានិយាមតឹងរឹងជាងសិទ្ធិដែលត្រូវបានផ្តល់ដោយមាត្រា១៤នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ។ យោងតាមអនុសញ្ញាសិទ្ធិមនុស្សអឺរ៉ុប (ECHR) វិញ មាត្រា៥(៣) មានគោលដៅ

---

[49] "ជនណាមួយដែលត្រូវបានចាប់ខ្លួន ឬត្រូវបានឃុំខ្លួន (...) មានសិទ្ធិទទួលការជំនុំជម្រះដោយគ្មានការអូសបន្លាយ ឬត្រូវដោះលែងនៅក្នុងពេលដំណើរការនៃនីតិវិធី" ។

ជាសវាងកុំឲ្យជនត្រូវចោទត្រូវបានឃុំខ្លួនរយៈពេលវែងពេក មុនការចាប់ផ្តើមនៃការជំនុំជម្រះ ហើយមាត្រា៦(១) ធានាឲ្យជនត្រូវចោទមិនស្ថិតក្នុងស្ថានភាពមួយមិនច្បាស់លាស់នៅក្នុងរយៈពេលវែងដែរ[50]។

៧០. យោងតាមបទដ្ឋាននេះ រយៈពេលនៃការឃុំខ្លួនត្រូវតែសមហេតុសមផលទៅតាមកាលៈទេសៈទាំងឡាយនៃរឿងក្តីនីមួយៗ[51]។ រយៈពេលនេះគឺចាប់ផ្តើមរាប់តាំងពីថ្ងៃចាប់ខ្លួន ឬ/និង ថ្ងៃឃុំខ្លួន រហូតទៅដល់កាលបរិច្ឆេទនៃសាលក្រមរបស់សាលាដំបូង[52]។ ប្រសិនបើពេលវេលានៃការឃុំខ្លួនបណ្តោះអាសន្នហួសរយៈពេលដែលត្រឹមត្រូវនេះ ការឃុំខ្លួននេះក្លាយទៅជាអំពើមួយដែលធ្វើឡើងតាមអំពើចិត្ត ហើយជននេះត្រូវតែបានដោះលែង។

៧១. នៅក្នុងករណីនេះ នីតិវិធីទាំងអស់ត្រូវបានពន្យារដោយសារតែអវត្តមាននៃការបកប្រែ ៖ លោក ខៀវ សំផន គ្មានលទ្ធភាពចូលរួមក្នុងនីតិវិធីស៊ើបសួរ ហើយម្យ៉ាងទៀត សវនាការលើបណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្នត្រូវបានលើកទៅថ្ងៃក្រោយ ដោយសារមូលហេតុនេះហើយ។ រហូតមកទល់ពេលនេះ មិនទាន់បានកំណត់កាលបរិច្ឆេទណាមួយ សំរាប់សវនាការខាងមុខនេះ។ អស់រយៈពេល៩ខែហើយដែល លោក ខៀវ សំផន ត្រូវបានឃុំខ្លួន ហើយរង់ចាំដំណោះស្រាយមួយដ៏ថិតថេរ ដោះស្រាយលើស្ថានភាពនេះ។ សហចៅក្រមស៊ើបអង្កេតទើបតែបញ្ជាក់ថាគ្មានដំណោះស្រាយណាត្រូវបានកំណត់ទេ។

## គ) ត្រូវតែដោះលែងលោក ខៀវ សំផន

### ១) ស្ថានភាពរបស់លោក ខៀវ សំផន

៧២. លោក ខៀវ សំផន ត្រូវបានឃុំខ្លួនតាំងពីខែវិច្ឆិកា ឆ្នាំ២០០៧។ ចាប់តាំងពីកាលបរិច្ឆេទនេះ គាត់គ្មានលទ្ធភាពប្រើប្រាស់សិទ្ធិរបស់គាត់យ៉ាងពិតប្រាកដបានឡើយទេ។ ដោយគ្មានជំនួយពីសំណាក់មេធាវីរបស់គាត់ គាត់មិនអាចចូលរួមយ៉ាងសកម្មនៅក្នុងនីតិវិធីស៊ើបសួរ ហើយសូម្បីតែសិទ្ធិ

---

[50] តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECHR) Stogmuller c/Autriche ឆ្នាំ១៩៨០ ។

[51] គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប (ECHR) Stögmuller ទល់Autriche, (១៦០២:៦២) សាលក្រមចុះថ្ងៃទី១០ វិច្ឆិកា ១៩៦៩ ។

[52] គណៈកម្មការសិទ្ធិមនុស្សអឺរ៉ុប (ECHR) Wehmoff តទល់នឹង ប្រទេសអាឡឺម៉ង់ កថាខណ្ឌ ៩។

ទទួលបាននូវសវនាការដើម្បីកំណត់ថាការឃុំខ្លួនរបស់គាត់ស្របទៅតាមច្បាប់ឬទេ ក៏គាត់គ្មានសិទ្ធិនោះដែរ។

៧៣. នៅក្នុងដីកាសម្រេចដែលយើងប្ដឹងឧទ្ធរណ៍នេះ សហចៅក្រមស៊ើបអង្កេតអះអាងថា មិនអាចធានាការបកប្រែសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ដោយដោយការនេះមិនប៉ះពាល់ដល់សិទ្ធិទទួលបាននូវជំនុំជម្រះក្នុងរយៈពេលសមស្របឡើយ។ ក៏ប៉ុន្តែ សហមេធាវីការពារក្ដីអះអាងថា មិនអាចមានការជំនុំជម្រះណាមួយប្រកបដោយយុត្តិធម៌ទេប្រសិនបើគ្មានការបកប្រែនេះហើយ អ.វ.ត.ក.បានមានកាតព្វកិច្ចធានាអំពីការបកប្រែនេះ តាំងពីរាប់ខែរួចមកហើយ។

៧៤. ដូច្នេះហើយ ស្ថានភាពនេះគ្មានច្រកចេញទេ ហើយក្នុងនាមសិទ្ធិទទួលបានការជំនុំជម្រះដែលប្រកបដោយយុត្តិធម៌ លោក ខៀវ សំផន ត្រូវតែទទួលបានការដោះលែង។

## ២) ត្រូវតែដោះលែងលោក ខៀវ សំផន

៧៥. សិទ្ធិរបស់លោក ខៀវ សំផន ត្រូវបានរំលោភជាច្រើនសារ ហើយគាត់មានសិទ្ធិទទួលបាននូវសំណងការខូចខាត ៖ បើតាមគណៈកម្មាធិការសិទ្ធិមនុស្ស មាត្រា២កថាខ័ណ្ឌទី៣ នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ "ទាមទារឲ្យភាគីហត្ថលេខីផ្ដល់សំណងការខូចខាតដល់ជនណាដែលសិទ្ធិរបស់ជននេះដូចត្រូវបានចែងក្នុងកតិកាសញ្ញានេះ ត្រូវបានរំលោភបំពាន។ (...) កតិកាសញ្ញានេះទទួលស្គាល់ជាទូទៅនូវកាតព្វកិច្ចផ្ដល់សំណងខូចខាតមួយដែលសមហេតុផល"[53]។

៧៦. នៅពេលដែលការប៉ះពាល់ទៅលើសិទ្ធិការពារក្ដីសំខាន់ខ្លាំងពេក ហើយមិនអាចធានាយុត្តិធម៌នៃការជំនុំជម្រះទៀតទេ ពិតជាត្រូវបញ្ឈប់ដំណើរការនៃនីតិវិធី។ ទ្រឹស្ដីនៃការរំលោភលើដំណើរការអនុវត្តបាននៅក្នុងករណីពីរគឺ ៖ (១) ពេលដែលការយឺតយ៉ាវនាំឲ្យ ការជំនុំជម្រះប្រកបដោយយុត្តិធម៌មិនអាចកើតឡើងបាន និង (២) ពេលដែលនៅក្នុងកាលៈទេសៈនៃរឿងក្ដីមួយ ដោយសារ

---

[53] សេចក្ដីកត់សម្គាល់ទូទៅលេខ៣១ អំពីខ្លឹមសារនៃកាតព្វកិច្ចទូទៅតាមផ្លូវច្បាប់ ដែលភាគីហត្ថលេខីនៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយត្រូវតែគោរព (សម័យប្រជុំទី២៤) អង្គការសហប្រជាជាតិ ឯកសារ HRI/GEN/1/Rev.7 (ឆ្នាំ២០០៤) កថាខ័ណ្ឌទី១៦ ។

កំហុសឬភាពមិនប្រក្រតីដែលត្រូវបានប្រព្រឹត្តឡើងនៅដំណាក់កាលបុរេជំនុំជម្រះ ការបន្តនៃការជំនុំជម្រះអាចប៉ះពាល់ដល់អត្ថន័យនៃយុត្តិធម៌របស់តុលាការមួយ" (ការបកប្រែក្រៅផ្លូវការ)[54]។

៧៧. នៅក្នុងករណីយើងនេះ មានទាំងពីរទ្រង់ទ្រាយនៃការរំលោភលើដំណើរការនេះ។ សហចៅក្រមស៊ើបអង្កេតបានទទួលស្គាល់ថា នៅពេលអនាគត នឹងគ្មានធ្វើការបកប្រែឯកសារទាំងអស់ឡើយ ពីព្រោះ អ.វ.ត.ក.គ្មានធនធាន និងថវិការទេ។ ប៉ុន្តែ បើគ្មានការបកប្រែនេះ ក៏គ្មានការជំនុំជម្រះប្រកបដោយយុត្តិធម៌ទៀតទេ។

៧៨. កន្លងមកនេះ អង្គជំនុំជម្រះដំបូងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ បានប្រព្រឹត្តអនុវត្តទ្រឹស្តីនេះ។ នៅក្នុងរឿងក្តីនោះ ជនជាប់ចោទមិនបានមានសិទ្ធិពេញលេញក្នុងការពិនិត្យឯកសារដោះបន្ទុកនៃសំណុំរឿងរបស់គាត់នៅគ្រប់ដំណាក់កាលនៃនីតិវិធី។ ដូច្នេះហើយ អង្គជំនុំជម្រះដំបូងបានសំរេចឲ្យបញ្ឈប់នីតិវិធី[55] ហើយក៏បានបង្គាប់ឲ្យដោះលែងជនជាប់ចោទ ដែលនេះជា "ផលវិបាកដែលមិនអាចចៀសវាងបានទេ" នៃការសម្រេចយ៉ាងនេះរបស់អង្គជំនុំជម្រះ[56]។

៧៩. សហមេធាវីជឿជាក់ថា អង្គបុរេជំនុំជម្រះមិនអាចប្រព្រឹត្តខុសពីនេះ នៅក្នុងករណីនេះ។

---

[54] តុលាការព្រហ្មទណ្ឌអន្តរជាតិប្រទេសរ្វ៉ានដា រដ្ឋអាជ្ញា c/ Barayagwiza សាលដីកានៃសាលាឧទ្ធរណ៍ កថាខ័ណ្ឌទី៧៧ ។

[55] តុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋអាជ្ញា c/Thomas Lubanga Dyilo - ការសំរេចស្តីពីផលវិបាកនៃការដែលមិនបានបង្ហាញឯកសារដោះបន្ទុក កិច្ចព្រមព្រៀងដូចមានចែងនៅក្នុងមាត្រា៥៤(៣)(ង) ហើយការអនុវត្តនៃការបញ្ឈប់ការចោទប្រកាន់នៃជនជាប់ចោទ និងបញ្ហាផ្សេងៗលើកឡើងនៅសន្និសីទស្តីពីលក្ខន្តិកៈនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨ កថាខ័ណ្ឌ៩០-៩១ ។

[56] តុលាការព្រហ្មទណ្ឌអន្តរជាតិ រដ្ឋអាជ្ញា c/Thomas Lubanga Dyilo- សេចក្តីសំរេចស្តីពីការដោះលែងរបស់ Thomas Lubanga Dyilo ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០០៨ - កថាខ័ណ្ឌ៣២ ។

## V. សេចក្ដីសន្និដ្ឋាន

សហមេធាវីការពារក្ដីក៏សូមទាំងក្ដីគោរពអង្គបុរេជំនុំជម្រះ មេត្តា ៖

- <u>ទុកជាមោឃៈ</u> នូវការបដិសេធនៃការស្នើសុំឱ្យមានការបកប្រែនៃសំណុំរឿងព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ដោយលើកឡើងពីកង្វះខាតនៃមូលដ្ឋានផ្លូវច្បាប់ និងការរំលោភទៅលើសិទ្ធិមនុស្សនៃភាគីការពារក្ដី ។
- <u>សម្គាល់</u> នូវការរំលោភសិទ្ធិការពារក្ដីផ្សេងៗដែលបណ្ដាលមកពីអវត្តមាននៃការបកប្រែ។
- <u>បង្គាប់ឱ្យដោះលែង</u>លោក ខៀវ សំផន ភ្លាមៗ និងដោយគ្មានលក្ខខណ្ឌ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ខែកក្កដា ឆ្នាំ២០០៨

មេធាវី ស សូវាន មេធាវី Jacques VERGÈS